# ពន្ធនាគារក្រុង Seattle

## ព័ត៌មានមូលដ្ឋាន

*សំគាល់ : ព័ត៌មានសាវតា និងព័ត៌មានលំអិតបន្ថែមទៀត អាចទទួលបានតាមគេហទំព័រ www.Seattle.gov/municipaljail/*

នៅ**ថ្ងៃទី 1 ខែ មករា ឆ្នាំ 2013** ខោនធី King នឹងឈប់ទទួលអ្នកទោសបទល្មើសមជ្ឈឹមពីទីក្រុងទាំងឡាយនៅក្នុងខោនធី នៅពន្ធនាគារណាមួយក្នុងចំណោមពន្ធនាគារទាំងពីររបស់ខោនធី ។ សេចក្តីសម្រេចរបស់ខោនធី បង្ខំឱ្យ Seattle និងទីក្រុងផ្សេងទៀតទាំងអស់ឱ្យធ្វើការចាត់ចែងផ្សេងទៀតសម្រាប់ ជនល្មើសមជ្ឈឹមរបស់ពួកគេ ។ គ្រែសម្រាកនៅក្នុងពន្ធនាគារជំនួស ត្រូវតែមានឱ្យបាននៅឆ្នាំ 2013 ។ ទីក្រុង Seattle មានជម្រើសពីរដើម្បីទទួលបានទីតាំងពន្ធនាគារថ្មី។ ទីមួយ **ត្រូវសាងសង់នៅភាគខាងកើត និងខាងជើងទីក្រុង ហើយត្រូវធ្វើប្រតិបត្តិការពន្ធនាគារថ្មីនោះជាមួយគ្នា** ដោយមានសេចក្តីសម្រេចចិត្តនៅមុនខែ កក្កដា នេះ ។ ទីពីរ ត្រូវរក**សាងសង់ពន្ធនាគារផ្ទាល់របស់ខ្លួន**។ អាគាររួមគ្នានេះនឹងផ្តល់ឱ្យមានគ្រែ 645 និងប្រហែលជាមានទីតាំងនៅក្នុង ទីក្រុង Seattle ឬភាគខាងជើង ឬខាងកើតខោនធី King ។ ពន្ធនាគារតែមួយគត់របស់ទីក្រុង Seattle នឹងត្រូវការគ្រែប្រហែលជា 445 ។

ក្រុង បានសាងសង់គំរូអាគារពន្ធនាគាររបស់ខ្លួនក្នុងបរិវេណ Regional Justice Center (មជ្ឈមណ្ឌលយុត្តិធម៌ក្នុងតំបន់) របស់ខោនធី – ដែលជាអាគារមានកម្ពស់ច្រើនជាន់ដែល ត្រូវបានចាត់ទុកថាជាពន្ធនាគារគំរូមួយ ។ ក្រុងជឿថា ពន្ធនាគារកម្ពស់ច្រើនជាន់នេះនឹងត្រូវចំណាយអស់តិចក្នុងការសាងសង់ និងប្រតិបត្តិការ ក៏ដូចជាមានសុវត្ថិភាពជាង ដល់អ្នកទោស និង មន្ត្រីធនាគារ ។ (អ្នកផ្តល់ប្រឹក្សានឹងធ្វើរបាយការណ៍ពីភាពខុសគ្នាលើតម្លៃដែលអាចមាននៅក្នុងខែ កក្កដា) ។ ពន្ធនាគារកម្ពស់ច្រើនជាន់នេះ ត្រូវការផ្ទៃដីសាងសង់យ៉ាងហោចណាស់ប្រាំពីរអេឃើ ។ ក្រុងជាបឋម បានកំណត់ទីតាំងដែល **មានទំហំប្រាំពីរអេឃើ នៅជិតតំបន់សំខាន់** ហើយ**នៅលើដីដែលជាតំបន់ពាណិជ្ជកម្ម ឬឧស្សាហកម្ម (ក្រុងបានបំបែកចេញពីតំបន់ដែលប្រជាពលរដ្ឋ រស់នៅ)** ។ ចាប់ផ្តើមឡើងជាមួយនឹងទីតាំងដែលមានសក្តានុពលចំនួន 35 ក្រុងបានវិភាគទីតាំងនីមួយៗ និងបានជ្រើសរើសទីតាំងចំនួនបួនដែលអាចធ្វើការសាងសង់បាន :

11762 Aurora Ave. N.
1600 W. Armory Way
Highland Park Way Southwest និង West Marginal Way
9501 Myers Way S.

ក្រុងកំពុងតែប្រមូលយោបល់ត្រឡប់ អំពីទីតាំងទាំងនោះ តាមរយៈវេទិកាសាធារណៈចំនួនបួន :

ថ្ងៃទី 26 ខែ មិថុនា – Machinists Hall
ថ្ងៃទី 12 ខែ កក្កដា – North Seattle Community College
ថ្ងៃទី 26 ខែ កក្កដា – South Seattle Community College
ថ្ងៃទី 30 ខែ កក្កដា – Seattle Center Exhibition Hall

ាសាធារណៈបន្ថែមចំនួនពីរទៀតនៅចុងរដូវក្តៅ ឬដើមរដូវស្លឹកឈើជ្រុះ នឹងអនុញ្ញាតឱ្យសហគមន៍ផ្តល់ការចូលរួមលើដែនកំណត់ ការងារសម្រាប់ **environmental impact**
**ent (របាយការណ៍ផលប៉ះពាល់បរិស្ថាន)** ។ ប្រជាជនក៏អាចផ្តល់ការឆ្លើយតបតាមរយៈ ទំព័រផ្តល់មតិ និងចម្លល់តាមវេបសាយ [www.seattle.gov/municipaljail/](www.seattle.gov/municipaljail/) ។
**ជ្រើសរើសទីតាំងចុងក្រោយ ក្រុមប្រឹក្សាក្រុង នឹងរៀបចំសវនាការ ដែលសវនាការទាំងនេះត្រូវបានរំពឹងទុកថាធ្វើឡើងនៅឆមាសទីមួយឆ្នាំក្រោយ** ។

ក្នុងរយៈពេលជាងមួយទសវត្សរ៍កន្លងទៅនេះ **ក្រុងបានកាត់បន្ថយចំនួនអ្នកទោសបទល្មើសមជ្ឈឹមបានចំនួន 38%** ។ ជាលទ្ធផលពន្ធនាគារ ជាមធ្យម ដាក់អ្នកទោសបទល្មើសមជ្ឈឹមតិចជាង 300 នាក់ ដែលធ្លាក់ចុះពីចំនួនជាង 450 នាក់ ក្នុងរយៈពេល 10 ឆ្នាំកន្លងទៅនេះ ។ ទោះយ៉ាងណា **ច្បាប់រដ្ឋទាមទារឱ្យជាប់ពន្ធនាគារ ចំពោះជនមួយចំនួន ដែលត្រូវបានចោទប្រកាន់ពីបទល្មើសមជ្ឈឹម** ដែលមានដូចជា : អំពើហិង្សាក្នុងគ្រួសារ ឬជនទាំងឡាយណាដែលធ្លាប់ទទួលទោសលើសពីមួយដងពីបទបើកបរក្រោមឥទ្ធិពលគ្រឿងស្រវឹង ។ មួយភាគបីនៃជនដែលមានឈ្មោះក្នុងបញ្ជីពន្ធនាគារ ត្រូវបានដោះលែង ឬឱ្យនៅក្រៅឃុំ ប៉ុន្តែក្រោយមកមិនបានបង្ហាញខ្លួននៅចំពោះមុខតុលាការ ។ ទោះបីជាមានការផ្លាស់ប្តូរគ្នាចូលទៅកាន់ពន្ធនាគារអាចប៉ះពាល់ដល់ទំហំធនាគារក៏ដោយ ក៏ជម្រើសទាំងនេះ មិនអាចប្តូរតម្រូវការឱ្យមានពន្ធនាគារនោះឡើយ ។

**ជាមធ្យម អ្នកទោសជាប់ពន្ធនាគាចំនួន 10 ថ្ងៃ** ។ មួយចំនួនត្រូវបានកត់ត្រា និងដោះលែងវិញក្នុងរយៈពេល 48 ម៉ោង ។ អ្នកខ្លះទៀតត្រូវជាប់រហូតដល់មួយឆ្នាំ ។ ជាញឹកញាប់ មនុស្សភាគច្រើនបំផុត ត្រូវបានកត់ត្រាពីការចោទប្រកាន់ពីបទល្មើសមជ្ឈឹមពាក់ព័ន្ធទៅនឹងទ្រព្យសម្បត្តិ (ដូចជា លួចទំនិញក្នុងហាងជាដើម) បើកបរក្រោមឥទ្ធិពលគ្រឿងស្រវឹង ការបំពារបំពានតួតតាច អំពើហិង្សាក្នុងគ្រួសារ និងការរំលោភបំពានល្មើស ។

# លក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសទីតាំង

នៅដើមឆ្នាំនេះ ក្រុងបានចាប់ផ្តើមសំឡឹងរកមើលទីតាំងដែលមានសក្តានុពល សំរាប់សាងសង់ពន្ធនាគារកម្ពស់ច្រើនជាន់ ។ លក្ខណៈវិនិច្ឆ័យបឋម គឺថា ទីតាំង :

- ត្រូវតែស្ថិតនៅក្នុងតំបន់ពាណិជ្ជកម្ម ឬឧស្សាហកម្ម
- ផ្តល់ផ្លូវចេញចូលងាយស្រួលទៅកាន់ផ្លូវធំ និង
- ជាទីតាំងមួយកន្លែងមានទំហំបួនទៅប្រាំអេឃឺ ឬជាទីតាំងច្រើនរួមបញ្ចូលគ្នាតែមួយ ។

មានទីតាំងចំនួន 35 កន្លែងដែលសមស្របទៅនឹងលក្ខណៈវិនិច្ឆ័យមូលដ្ឋានទាំងនេះ ។ បន្ទាប់មក ក្រុងបានសិក្សាទៅលើទីតាំងនីមួយៗ ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យបន្ថែមទាំងនេះ :

| | | |
|---|---|---|
| ទំហំទីតាំង | ភាពងាយស្រួលរបស់ទីតាំង | រូបសណ្ឋានរបស់ទីតាំង |
| មធ្យោបាយដឹកជញ្ជូនសាធារណៈ | ស្របគ្នាជាមួយការប្រើប្រាស់នៅជិតៗ | មានលក្ខណៈជាបច្ចេកទេសភូមិសាស្ត្រ |
| លក្ខខណ្ឌបរិស្ថាន | ជាការពង្រីកនៃការអភិវឌ្ឍន៍បច្ចុប្បន្ន | ការផ្លាស់ប្តូរអាជីវកម្ម និងអ្នកជួល |
| ចំណាយទិញតិច | ជាតំបន់ត្រូវអភិវឌ្ឍន៍ | |

បន្ទាប់ពីធ្វើការវិភាគរួចរាល់ ក្រុងបានកំណត់បានទីតាំងចំនួនបួនកន្លែងដែលជាទីតាំងអាចធ្វើការសាងសង់បាន ចេញពីទីតាំងទាំង 35 កន្លែង :

- 11762 Aurora Ave. N.
- 1600 W. Armory Way
- Highland Park Way Southwest & West Marginal Way
- 9501 Myers Way S.

# ក្របខណ្ឌពេលវេលា

ក្រុងបានបង្កើតក្របខណ្ឌពេលវេលាខាងក្រោមនេះ ដើម្បីបើកពន្ធនាគាថ្មីឱ្យបាននៅថ្ងៃទី 1 ខែ មករា ឆ្នាំ 2008 :

- បង្កើតទីតាំងជម្រើស និងកំណត់ទីតាំងដែលពេញចិត្ត - ពីខែ មករា ឆ្នាំ 2008 ដល់ត្រីមាសទីពីរឆ្នាំ 2009
- បញ្ចប់ការសិក្សាជាក់ស្តែងលើទីក្រុង Seattle/ភាគខាងកើតទីក្រុង - ខែ កក្កដា ឆ្នាំ 2008
- បញ្ចប់ការវាយតម្លៃលើចំណាយប៉ាន់ស្មានចំណាយសាងសង់អាគារកម្ពស់ច្រើនជាន់ និងអាគារកម្ពស់ច្រើនជាន់បំពាក់ជណ្តើរយន្ត - ខែ កក្កដា ឆ្នាំ 2008
- រៀបចំវេទិកាសាធារណៈលើកដំបូង - ខែ មិថុនា/កក្កដា ឆ្នាំ 2008
- ចេញផ្សាយពង្រៀងសេចក្តីជូនដំណឹងពីទំហំសំរាប់ environmental impact statement (របាយការណ៍ផលប៉ះពាល់បរិស្ថាន) ស្វះស្វែងប្រមូលមតិយោបល់សាធារណៈ - ត្រីមាសទីបី ឆ្នាំ 2008
- ចេញផ្សាយ environmental impact statement (របាយការណ៍ផលប៉ះពាល់បរិស្ថាន) ព្រាង - ត្រីមាសទីមួយ ឆ្នាំ 2009
- ប្រមូលមតិយោបល់សាធារណៈទៅលើពង្រៀង environmental impact statement (របាយការណ៍ផលប៉ះពាល់បរិស្ថាន) - ត្រីមាសទីមួយ ឆ្នាំ 2009
- បញ្ចូលយោបល់ត្រឡប់របស់សធារណៈជនទៅក្នុង environmental impact statement (របាយការណ៍ផលប៉ះពាល់បរិស្ថាន) ចុងក្រោយ - ត្រីមាសទីពីរ ឆ្នាំ 2009
- កំណត់ទីតាំងដែលពេញចិត្ត - ត្រីមាសទីពីរ ឆ្នាំ 2009
- រៀបចំស្ថាបត្យកម្ម និងវិស្វកម្ម - ត្រីមាសទីពីរ ឆ្នាំ 2009 ដល់ខែ មិនា ឆ្នាំ 2010
- ដាក់ដេញថ្លៃការងារសាងសង់ - ខែ មិនា ឆ្នាំ 2010 ដល់ខែ កក្កដា ឆ្នាំ 2010
- ការសាងសង់ - ខែ កក្កដា ឆ្នាំ 2010 ដល់ខែ កក្កដា ឆ្នាំ 2012
- រៀបចំការចូលកាន់កាប់ - ខែ កក្កដា ឆ្នាំ 2012 ដល់ខែ ធ្នូ ឆ្នាំ 2012
- បើកឱ្យប្រើប្រាស់ពន្ធនាគារក្រុង Seattle - ខែ មករា ឆ្នាំ 2013